**ក្រសួងសុខាភិបាល**
លេខ ៤៨៩ សណរក/ប្រកស

# ប្រកាស
## ស្តីពី
## ការផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ សម្រាប់សហគ្រាសនិងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុក ផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្ស
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផល សម្រាប់ចិញ្ចឹមទារក និងកុមារ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្តីពីការអនុវត្ត និងសម្រប សម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចាប់ពីកសិដ្ឋានផលិតដល់តុបរិភោគ
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល។

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងការពារសុខភាពមនុស្ស និងធានាថាផលិតផលចំណីអាហារមានអនាម័យ សុវត្ថិភាព និងគុណភាព តាមរយៈការផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅគ្រប់គ្រងលើប្រព័ន្ធផលិត(GHP) និងស្តុកទុក(GSP) ចំពោះផលិតផលចំណីអាហារ សម្រាប់សហគ្រាស សិប្បកម្មផលិតចំណីអាហារ ឃ្លាំងស្តុកផលិតផលចំណីអាហារ និងឃ្លាំងស្តុកផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

**ប្រការ៣ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តគ្រប់សហគ្រាសនិងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងប្រកាសនេះរួមមាន៖

- **សហគ្រាសនិងសិប្បកម្មផលិតចំណីអាហារ** សំដៅដល់អគារ ឬទីកន្លែង សម្រាប់ផលិត ការកែច្នៃវត្ថុធាតុដើម ឬផលិតផលពាក់កណ្តាលសម្រេចឱ្យទៅជាផលិតផលចំណីអាហារថ្មីមួយ ដើម្បីបំពេញតម្រូវការទីផ្សារ។
- **ឃ្លាំងស្តុក** សំដៅដល់អគារ បន្ទប់ ឬចំណែកដែលតម្រូវលើបរិមាណផលិតផលចំណីអាហារដែលត្រូវបានស្តុកទុកមុននឹងធ្វើការចែកចាយលក់នៅលើទីផ្សារ ឬកន្លែងផ្សេងៗ នៃក្រុមហ៊ុននាំចូលផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។
- **ផលិតផលចំណីអាហារ** សំដៅដល់សារធាតុ ឬផលិតផលទាំងឡាយណា ដែលបានកែច្នៃរួចទាំងស្រុង ឬកែច្នៃបឋម ឬមិនទាន់កែច្នៃ ក្នុងគោលបំណងបរិភោគដោយមនុស្ស រាប់ទាំងភេសជ្ជៈ ស្ករកៅស៊ូសម្រាប់ទំពារ និងសារធាតុផ្សេងៗដែលប្រើប្រាស់ក្នុងការផលិត រៀបចំ ឬប្រព្រឹត្តកម្មចំណីអាហារ។
- **សុវត្ថិភាពចំណីអាហារ** សំដៅដល់ការអនុវត្តដំណើរការធានាថាចំណីអាហារមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់នៅពេលដែលត្រូវបានយកទៅធ្វើការរៀបចំ ឬបរិភោគស្របតាមកម្មវត្ថុប្រើប្រាស់របស់ចំណីអាហារនោះ។
- **គោលការណ៍អនុវត្តអនាម័យល្អ (GHP)** សំដៅដល់គ្រប់លក្ខខណ្ឌ និងវិធានការចាំបាច់ទាំងអស់ដើម្បីធានាថាចំណីអាហារមានសុវត្ថិភាពនៅគ្រប់ដំណាក់កាលនៃខ្សែសង្វាក់ផលិតកម្មចំណីអាហារដូចមានក្នុងឧបសម្ព័ន្ធ១។

**-តារាងលក្ខណៈវិនិច្ឆ័យ** (Check List) សំដៅដល់តារាងលក្ខណៈវិនិច្ឆ័យសុវត្ថិភាពចំណីអាហារ(ភ្ជាប់ក្នុងឧបសម្ព័ន្ធ២ និងឧបសម្ព័ន្ធនៃប្រកាសនេះ)។

**ប្រការ៥ .-**

ម្ចាស់ ឬអ្នកគ្រប់គ្រងសហគ្រាសនិងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ត្រូវតែស្នើសុំវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ឃ្លាំងស្តុក (GSP) ផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវដាក់ពាក្យស្នើសុំមកក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង)។

**ប្រការ៦ .-**

ក្រសួងសុខាភិបាលនឹងផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ឃ្លាំងស្តុក(GSP)ផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ជូនដល់ម្ចាស់សហគ្រាសនិងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារក្នុងរយៈពេល២០ថ្ងៃ(ថ្ងៃធ្វើការ)បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ។

**ប្រការ៧ .-**

លក្ខខណ្ឌតម្រូវក្នុងការស្នើសុំវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ឃ្លាំងស្តុក(GSP)ផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវភ្ជាប់មកជា មួយនូវឯកសារដូចខាងក្រោម:

១- ពាក្យស្នើសុំ
២- រូបថត ៤សម x ៦សម(អាវធំ ឬអាវសឺមី) ចំនួន០៣សន្លឹក
៣- ប្រវត្តិរូបសង្ខេបមានបិទរូបថត
៤- ឯកសារថតចំលងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
៥- គំនូសបំព្រួញបញ្ជាក់ទីតាំងរបស់សហគ្រាស ឬសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ
៦- រូបថតរួមមានឈ្មោះសហគ្រាស ឬសិប្បកម្ម កន្លែងផលិត ឧបករណ៍ សម្ភារផ្សេងៗ កន្លែងស្តុកវត្ថុធាតុដើម កន្លែងស្តុកផលិតផលសម្រេច និងបន្ទប់អនាម័យ
៧- រូបថតរួមមានឈ្មោះឃ្លាំងស្តុក និងកន្លែងស្តុក
៨- ប័ណ្ណប៉ាតង់។

**ប្រការ៨ .-**

វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ឃ្លាំងស្តុក(GSP)ផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ មានទំហំក្រដាស A4 នឹងមានហត្ថលេខារបស់រដ្ឋមន្ត្រី និងត្រាក្រសួងសុខាភិបាល។

វិញ្ញាបនបត្រនេះត្រូវមានព័ត៌មានដូចខាងក្រោម ៖

- មានពាក្យ " វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP)"
- មានពាក្យ " វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អឃ្លាំងស្តុក(GSP)"
- ឈ្មោះ និងរូបថតរបស់ម្ចាស់
- ឈ្មោះ និងទីតាំងរបស់សហគ្រាស ឬសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ។
- ថ្ងៃ ខែ ឆ្នាំ នៃការផ្តល់វិញ្ញាបនបត្រ និងរយៈពេលសុពលភាពនៃវិញ្ញាបនបត្រ។
- ឈ្មោះរបស់អ្នកចុះហត្ថលេខា និងត្រា។

វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ឃ្លាំងស្តុក(GSP)ផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវដាក់តាំងបង្ហាញនៅក្នុងសហគ្រាសនិងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

**ប្រការ៩ .-**

វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ឃ្លាំងស្តុក(GSP)ផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារមានសុពលភាព ០២ ឆ្នាំ។ ក្នុងករណីសុំបន្តសុពលភាពវិញ្ញាបនបត្រសហគ្រាស និងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវស្នើសុំជាថ្មីមកក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង) ឱ្យបាន៣០ថ្ងៃមុនផុតសុពលភាព។

**ប្រការ១០ .-**

ក្រសួងសុខាភិបាលនឹងដកហូតវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ឃ្លាំងស្តុក(GSP)ផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ប្រសិនបើម្ចាស់សហគ្រាស និងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ មិនបានគោរពតាមដោយខ្ជាប់ខ្ជួននូវលក្ខខណ្ឌតម្រូវផ្សេងៗដូចដែលមានចែងនៅក្នុងឧបសម្ព័ន្ធ១នៃប្រកាសនេះ ឬក្នុងករណីរកឃើញថាផលិតផលចំណីអាហារនោះមានផលប៉ះពាល់ដល់សុខភាពអ្នកបរិភោគ។ ក្នុងករណីនេះម្ចាស់សហគ្រាស សិប្បកម្មផលិតផលចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវប្រមូលផលិតផលរបស់ខ្លួនត្រឡប់មកវិញដោយសហការជាមួយក្រសួងពាក់ព័ន្ធ។

**ប្រការ១១ .-**

ការបង់ថ្លៃលើការដាក់ពាក្យសុំ ការផ្តល់ និងការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អសម្រាប់ឃ្លាំងស្តុក(GSP) ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបន្ទុករបស់

ម្ចាស់សហគ្រាសនិងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

**ប្រការ១២ .-**

ភ្នាក់ងារត្រួតពិនិត្យចំណីអាហារមានតួនាទី និងសិទ្ធិអំណាច ដើម្បីចុះត្រួតពិនិត្យ វាយតម្លៃលក្ខខណ្ឌវិនិច្ឆ័យអនាម័យ និងសុវត្ថិភាពចំណីអាហារដូចមានចែងក្នុងឧបសម្ព័ន្ធ២ និង៣នៃប្រកាសនេះ។

**ប្រការ១៣ .-**

ការចុះត្រួតពិនិត្យមានជាអាទិ៍៖

-បរិវេណនៃសហគ្រាស សិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ

-កន្លែងស្តុកទុកវត្ថុធាតុដើម

-ឧបករណ៍ បរិក្ខារ និងសម្ភារប្រើប្រាស់

-ផលិតកម្ម និងការត្រួតពិនិត្យដំណើរការផលិតកម្ម

-ការវេចខ្ចប់

-អនាម័យដំណើរការផលិតកម្ម

-ការថែទាំ ការសំអាត និងការសម្លាប់មេរោគ

-អនាម័យកន្លែងស្តុកទុកក្នុងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ។

**ប្រការ១៤ .-**

ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ ត្រូវស្លៀកពាក់ឯកសណ្ឋានដូចមានកំណត់នៅក្រោមបទប្បញ្ញត្តិជាធរមានរបស់ក្រសួងសុខាភិបាល។

ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ ត្រូវចូលទៅក្នុងសហគ្រាស សិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារនៅក្នុងម៉ោងធ្វើប្រតិបត្តិការផលិតកម្ម។

នៅក្នុងពេលចុះត្រួតពិនិត្យ ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ ត្រូវបំពេញភារកិច្ចដោយមានប្រតិបត្តិករធុរកិច្ចចំណីអាហារ ឬអ្នកតំណាងចូលរួម។

ភ្នាក់ងារត្រួតពិនិត្យចំណីអាហារ ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈនៅក្នុងការបំពេញភារកិច្ចរបស់ភ្នាក់ងារ។ ភ្នាក់ងារត្រួតពិនិត្យចំណីអាហារណាម្នាក់ ដែលលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធទៅនឹងអាជីវកម្មដែលស្ថិតនៅក្នុងបន្ទុករបស់ខ្លួន ក្រៅពីភារកិច្ចរបស់ខ្លួន ដើម្បីបង្ការ និងចុះត្រួតពិនិត្យលើអាជីវកម្ម ត្រូវផ្តន្ទាទោសទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៥ .-**

ម្ចាស់សហគ្រាសនិងសិប្បកម្មផលិតចំណីអាហារ និងឃ្លាំងស្តុកផលិតផលចំណីអាហារ ឬផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារមិនត្រូវយកវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GHP) និងវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អឃ្លាំងស្តុក(GSP)ផលិតផលចំណីអាហារ ឬផលិតសម្រាប់ចិញ្ចឹមទារក និងកុមារ ទៅផ្សព្វផ្សាយពាណិជ្ជកម្មដោយមានលក្ខណៈបំផ្លើសពីការពិត។

**ប្រការ១៦ .-**

បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ឬលក្ខខណ្ឌតម្រូវណាមួយនៅក្នុងប្រកាសនេះ ឬប្រព្រឹត្តបទល្មើសណាមួយ ត្រូវជាកពិន័យអន្តរកាល និងទោសស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗដែលមានជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៧ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលចែងផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨ .-**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១២កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២០

**ម៉ម ប៊ុនហេង**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ " ដើម្បីសហការ "
- សាលារាជធានី-ខេត្ត
- ដូចក្នុងប្រការ១៨ " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ និងកាលប្បវត្តិ